Declassified to Public
27 June 2019

E404/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 11 / 2016
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សម្ងាត់ |

# សេចក្តីសម្រេចលើការតែងតាំងអ្នកជំនាញដែលមានលេខសម្ងាត់ 2-TCE-1062

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យកោះហៅ 2-TCE-1062 (វឿន វុទ្ធី) ដើម្បីអនុញ្ញាតឱ្យភាគីសួរដេញដោលអំពីវិធីសាស្ត្រ និង ដំណើរការដែលបានប្រើប្រាស់ក្នុងការរៀបចំការសិក្សាអំពីជើងឯក[1]។ នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា អង្គជំនុំជម្រះកំពុងពិចារណាស្តាប់ចម្លើយ 2-TCE-1062 (វឿន វុទ្ធី) ក្នុងឋានៈជាអ្នកជំនាញក្នុងសំណុំរឿង ០០២/០២ និង បានអញ្ជើញភាគីឱ្យធ្វើសេចក្តីសន្និដ្ឋានទាក់ទិននឹងគុណវុឌ្ឍិរបស់គាត់[2]។ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ និងថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា បានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងលទ្ធភាពដែល 2-TCE-1062 (វឿន វុទ្ធី)[3] អាចធ្វើជាអ្នកជំនាញ។ ភាគីដទៃទៀតពុំបានដាក់សេចក្តីសន្និដ្ឋានឡើយ។

## ២. សារណា

២. សហព្រះរាជអាជ្ញា លើកឡើងថា 2-TCE-1062 (វឿន វុទ្ធី) "មានគុណវុឌ្ឍិក្នុងការផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញពាក់ព័ន្ធនឹងវិធីសាស្ត្រ ខ្លឹមសារ និង របកគំហើញនៃការសិក្សាអំពីជើងឯក"[4] ។ សហព្រះរាជអាជ្ញា បានលើកឡើងថា 2-TCE-1062 (វឿន វុទ្ធី) នឹងអាចជួយដល់អង្គជំនុំជម្រះឱ្យបានយល់ដឹងអំពីភស្តុតាងនៃការសិក្សាអំពីជើងឯក និង របាយការណ៍ដែលពាក់ព័ន្ធដោយផ្អែក

---

[1] សេចក្តីសម្រេចលើការទទួលយកជាឯកសារភស្តុតាងនូវឯកសារសិក្សាពីជើងឯក, ឯកសារ E404/4, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦។

[2] លោក វឿន វុទ្ធី, ឯកសារ E404/5, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦។

[3] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងឋានៈរបស់ វឿន វុទ្ធី, ឯកសារ E404/6, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ("សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា")។ សារណារបស់ នួន ជា ស្តីពីលទ្ធភាពនៃឋានៈជាអ្នកជំនាញរបស់ វឿន វុទ្ធី [ឯកសារ E404/5], ឯកសារ E404/7, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦ ("សារណារបស់ នួន ជា")។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសារណារបស់មេធាវីការពារក្តី នួន ជា ត្រូវបានដាក់ជាដំបូងក្រោមលេខសំណុំរឿងមិនត្រឹមត្រូវ និង ជាលទ្ធផលត្រូវបានទទួលដោយអង្គជំនុំជម្រះនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៦។

[4] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤។

លើចំណេះដឹង និង បទពិសោធន៍របស់អ្នកជំនាញលើបញ្ហានេះ ព្រមទាំងការបណ្តុះបណ្តាល និង តួនាទីការងារវិជ្ជាជីវៈរបស់គាត់ក្នុងវិស័យនេះ[5]។

៣. មេធាវីការពារក្តី នួន ជា លើកឡើងថា 2-TCE-1062 (វឿន វុទ្ធី) មាន "ជំនាញដែលមិនអាចបដិសេធបាន" ក្នុងផ្នែកការសិក្សាស្តីពីអដ្ឋិធាតុ ទោះជាយ៉ាងណាក្តី គាត់មិនសាកសមក្នុងការផ្តល់ភ័ស្តុតាងក្នុងឋានៈជាអ្នកជំនាញទាក់ទិនការសិក្សានៅជើងឯកឡើយ[6]។ មេធាវីការពារក្តី នួន ជា លើកឡើងថា ផ្ទុយទៅវិញ 2-TCE-1062 (វឿន វុទ្ធី) គួរមកផ្តល់សក្ខីកម្មជាសាក្សីលើអង្គហេតុ ដោយផ្អែកលើការដឹងឮជាបុគ្គលទាក់ទងការរៀបចំវិធីសាស្ត្រប្រើប្រាស់ក្នុងការសិក្សា និង លទ្ធផលនៃការសិក្សានៅជើងឯក[7]។ មេធាវីការពារក្តី នួន ជា យល់ឃើញថា 2-TCE-1062 (វឿន វុទ្ធី) មិនសមស្របក្នុងការផ្តល់ភ័ស្តុតាងជាអ្នកជំនាញ ដោយសារបទពិសោធន៍របស់គាត់ភាគច្រើនគឺទាក់ទងនឹងការសិក្សាពីឆ្អឹងត្រី និង កាកសំណល់ពីបុរាណ និងនរវិទ្យា ហើយគាត់ពុំមានបទពិសោធន៍ក្នុងការវិភាគអដ្ឋិធាតុ ជាពិសេសការកំណត់អត្តសញ្ញាណដំណើរទង្គិច ឬ មូលហេតុនៃការស្លាប់ដើម្បីជួយដល់កិច្ចការតុលាការនោះឡើយ ("កោសល្យវិច័យសាកសព")[8]។ លើសពីនេះទៀត មេធាវីការពារក្តី នួន ជា លើកឡើងថា 2-TCE-1062 (វឿន វុទ្ធី) មិនដែលទទួលបានការបណ្តុះបណ្តាលណាមួយទាក់ទងការស៊ើបអង្កេតឡើយ ហើយវាមិនច្បាស់ថាតើបទសម្ភាសន៍នានាដែលគាត់បានធ្វើដើម្បីបំពេញការងារកោសល្យវិច័យរបស់គាត់នោះបានធ្វើ "នៅមុនពេល នៅក្នុងអំឡុងពេល ឬនៅក្រោយពេលឈានដល់សេចក្តីសន្និដ្ឋានស្តីពីការគាស់រណ្តៅសព"[9]។ ជាចុងក្រោយ មេធាវីការពារក្តី នួន ជា យល់ឃើញថា ដំណើរការកោសល្យវិច័យ និង ដំណើរការស៊ើបអង្កេត "ត្រូវតែបំបែកចេញពីគ្នាទាំងស្រុង ដើម្បីធានាពីអព្យាក្រិតភាព និង ភាពសត្យានុម័តនៃការងារកោសល្យវិច័យ"[10]។

---

[5] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា,កថាខណ្ឌ ៥។

[6] សារណារបស់ នួន ជា, កថាខណ្ឌ ១៨។

[7] សារណារបស់ នួន ជា, កថាខណ្ឌ ២១។

[8] សារណារបស់ នួន ជា, កថាខណ្ឌ ១៩។

[9] សារណារបស់ នួន ជា, កថាខណ្ឌ ២០។

[10] សារណារបស់ នួន ជា, កថាខណ្ឌ ២០។

## ៣. ច្បាប់ជាធរមាន

៤. អង្គជំនុំជម្រះរម្លឹកថា វិធាន ៣១ នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះអាចស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញ " អំពីបញ្ហាដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក" (វិធាន ៣១(១) នៃវិធានផ្ទៃក្នុង) និង ត្រូវតែងតាំង អ្នកជំនាញដោយដីកាសម្រេចដែលចែងឱ្យច្បាស់អំពីភារកិច្ចរបស់អ្នកជំនាញ (វិធាន ៣១(៣) នៃវិធានផ្ទៃក្នុង)។ អនុលោមតាមវិធាន ៨០ស្ទួន(២) នៃវិធានផ្ទៃក្នុង "នៅពេលអង្គជំនុំជម្រះពិចារណាឃើញថា ការស្តាប់សក្ខីកម្មអ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះត្រូវបដិសេធសំណើសុំឱ្យកោះហៅបុគ្គលនោះ។ វិធានផ្ទៃក្នុងមិនបានកំណត់និយមន័យនៃអ្នកជំនាញ ឬ កំណត់ពីគុណវុឌ្ឍិអប្បបរមា ឬ បទពិសោធន៍របស់បុគ្គលណាម្នាក់ ដើម្បីទទួលបានការតែងតាំងជាអ្នកជំនាញនៅ អ.វ.ត.ក ទេ[11]។

៥. អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ អ្នកជំនាញគឺជាបុគ្គលម្នាក់ដែលមានចំណេះដឹងជាពិសេស មានបទពិសោធន៍ ឬ ជំនាញ ដែលអាចជួយអង្គជំនុំជម្រះក្នុងការយល់ដឹងទៅលើបញ្ហាជាក់លាក់ដែលចោទជាបញ្ហា ដែលតម្រូវឱ្យមានចំណេះដឹងពិសេសនៅក្នុងវិស័យជាក់លាក់ណាមួយ[12]។ អ្នកជំនាញផ្តល់នូវការបំភ្លឺ, នូវបរិបទ ឬ ជំនួយបន្ថែម ក្នុងគោលបំណងដើម្បីឱ្យអង្គជំនុំជម្រះអាច

---

[11] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88 ឯកសារ E388 ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៩ (សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88), សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 ឯកសារ E367 ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ (សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95) កថាខណ្ឌ ៦។

[12] *សូមមើល* សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88 កថាខណ្ឌ ១០, សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៧, សេចក្តីសម្រេចតែងតាំងអ្នកជំនាញ ឯកសារ E215 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ )សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ( ១៦ ,*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Popovic *និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-T សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីតាមវិធាន *៩៤ស្ទួន* ទាក់ទិននឹងសាក្សីជំនាញ Richard Butler របស់រដ្ឋអាជ្ញា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ (សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY) កថាខណ្ឌ ២៣ ,*រឿងក្តី Nahimana ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៩៨។

វាយតម្លៃទៅលើភស្តុតាងបាន[13]។ អង្គជំនុំជម្រះបានសម្រេចថា ក្នុងករណីដែលអ្នកជំនាញមានការយល់ដឹងផ្ទាល់ខ្លួនលើអង្គហេតុនានាពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ បន្ថែមទៅនឹងឋានៈជាអ្នកជំនាញនោះ គាត់អាចនឹងត្រូវចោទសួរអំពីអង្គហេតុទាំងនោះផងដែរ[14]។

៦. អង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេចថាតើ បុគ្គលណាម្នាក់អាចនឹងត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ ឬ យ៉ាងណា។ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះគឺថាតើអ្នកជំនាញដែលបានស្នើឡើងនោះ មានជំនាញ ឬ ការយល់ដឹងពាក់ព័ន្ធ ដែលអាចជួយអង្គជំនុំជម្រះក្នុងការស្វែងរកការពិត និង យល់ដឹងពីភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែរ ឬ ទេ[15]។ ក្នុងការសម្រេចថាតើ អ្នកជំនាញដែលបានស្នើឡើងមានជំនាញ ឬ ការយល់ដឹងពាក់ព័ន្ធដែរ ឬ ទេនោះ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាទៅលើប្រវត្តិរូបការងារ អត្ថបទនិពន្ធ ការបោះពុម្ពផ្សាយ ឬ ព័ត៌មានផ្សេងៗទៀត រួមទាំងតួនាទីពីមុនៗ និង បច្ចុប្បន្នរបស់អ្នកជំនាញដែលបានស្នើឡើង[16]។ លើសពីនេះទៀត ការដែលអ្នកជំនាញដែលបានស្នើឡើងធ្លាប់មានទំនាក់ទំនងជាមួយស្ថាប័ន

---

[13] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88 កថាខណ្ឌ ១0, សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៧, សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ១៦។

[14] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៧ ,សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ១៨, សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម TCE-33 ឯកសារ E283 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២0១៣ (សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម TCE-33) កថាខណ្ឌ ១៦។

[15] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88 កថាខណ្ឌ ១១ សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៨ ,*រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ 00១១៨/-0៧-២00៧-អ/ក.ត.វ. សាក្សី និង ការពារការវិធានសុំសំណើលើសម្រេចដ សេចក្តី.ស.ជ.អ អ្នកជំនាញ និង លើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សី និង អ្នកជំនាញ ឯកសារ E40/1 ចុះថ្ងៃទី ១0 ខែ មេសា ឆ្នាំ ២00៩ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ១៦។

[16] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-88 កថាខណ្ឌ ១១, សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៨, សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ១៥។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Zdravko Tolimir* សំណុំរឿងលេខ IT-05-88/2-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍អ្នកជំនាញរបស់ Ratko Skrbic ដោយមានមតិយោបល់ដោយឡែករបស់ចៅក្រម Mindua និង មតិជំទាស់របស់ចៅក្រម Nyambe ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២0១២ កថាខណ្ឌ ១៤, សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY កថាខណ្ឌ ២៣-២៤ ,*រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Vojislav Seselj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចលើឋានៈជាអ្នកជំនាញរបស់ Reynaud Theunens ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២00៨ (សេចក្តីសម្រេចលើ Reynaud Theunens នៅតុលាការ ICTY) កថាខណ្ឌ ២៨។

ខាងក្រៅ ឬ ថាបច្ចុប្បន្នកំពុងបំពេញការងារនៅការិយាល័យណាមួយនៃ អ.វ.ត.ក ពុំអាចដកគាត់ចេញពីការកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញទេ[17]។

## ៤. ការវិភាគ

៧. អង្គជំនុំជម្រះកត់សម្គាល់ថា 2-TCE-1062 (វឿន វុទ្ធី) គឺជាប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និង ជាប្រធានគម្រោងអភិរក្សអដ្ឋិធាតុនៅមន្ទីរពិសោធន៍ជើងឯក[18]។ លើសពីនេះទៀត 2-TCE-1062 (វឿន វុទ្ធី) ជាអ្នកត្រួតពិនិត្យ ទទួលបន្ទុកការសិក្សាស្តីពីជើងឯក ដែលមួយផ្នែកធំនៃការសិក្សានោះត្រូវបានទទួលយកជាភស្តុតាងរួចហើយក្នុងសំណុំរឿង00២/0២[19]។

៨. 2-TCE-1062 (វឿន វុទ្ធី) បានទទួលសញ្ញាប័ត្រផ្នែកបុរាណវិទ្យាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៅកម្ពុជា និង សញ្ញាប័ត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Universita degli Studi di Ferrara នៅអ៊ីតាលី ដែលក្នុងអំឡុងពេលនោះ គាត់បានសរសេរសារណាដែលមានចំណងជើងថា "*Zooarchaeological Study from Phum Snay: A Prehistoric Cemetry in Northwestern Cambodia, Excavation 2007*" ("ការសិក្សាឆ្អឹងសត្វនៅភូមិស្នាយ៖ រណ្តៅបុរេប្រវត្តិនៅពាយព្យនៃកម្ពុជា ការធ្វើកំណាយនៅឆ្នាំ២00៧")។ លើសពីនេះទៀត ពីឆ្នាំ ២0១0 ដល់ ២0១១ 2-TCE-1062 (វឿន វុទ្ធី) បានទទួលការបណ្តុះបណ្តាលអំពីការវិភាគអំពីឆ្អឹងសត្វ និង ការអភិរក្សឆ្អឹងមនុស្ស នៅដេប៉ាតឺម៉ង់នរវិទ្យានៃសាកលវិទ្យាល័យ Hawaii នៅអាមេរិក[20]។ ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ

---

[17] សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 កថាខណ្ឌ ៨, សេចក្តីសម្រេចតែងតាំងអ្នកជំនាញ កថាខណ្ឌ ១៥, សេចក្តីសម្រេចតែងតាំងអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៣, *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ 00១១៨/-0៧-២00៧-អវ.ស.ជ.អ/ក.ត.វ. សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និង អ្នកជំនាញ និង លើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សី និង អ្នកជំនាញ ឯកសារ E40 ចុះថ្ងៃទី 0៣ ខែ មេសា ឆ្នាំ ២00៩ ទំព័រ ៩, សេចក្តីសម្រេចលើ Reynaud Theunens នៅតុលាការ ICTY កថាខណ្ឌ ២៩។

[18] ប្រវត្តិរូបសង្ខេបរបស់ វឿន វុទ្ធី, ឯកសារ E3/10678។

[19] *សូមមើល* ឯកសារ E404/4, កថាខណ្ឌ ៥។

[20] ប្រវត្តិរូបសង្ខេបរបស់ វឿន វុទ្ធី, ឯកសារ E3/10678។

២00៩ គាត់បានចូលរួមក្នុងការធ្វើកំណាយជាច្រើន រួមទាំងនៅតំបន់បុរេប្រវត្តិនានានៅកម្ពុជា[21]។ 2-TCE-1062 (វឿន វុទ្ធី) មានឯកសារបោះពុម្ពផ្សាយជាច្រើនទាក់ទិននឹងការវិភាគអំពីឆ្អឹងត្រីដែលបានរកឃើញនៅតាមទីតាំងកំណាយវត្ថុបុរាណនៅកម្ពុជា ព្រមទាំងឯកសារបោះពុម្ពផ្សាយអំពីអដ្ឋិធាតុនៃត្រីទឹកសាបកម្ពុជា និង វត្ថុបុរាណ និង ឆ្អឹងសត្វនៅភូមិស្នាយ[22]។ អត្ថបទបោះពុម្ពផ្សាយថ្មីៗរបស់គាត់ ទាក់ទិននឹងការវិភាគឆ្អឹងមនុស្ស ដែលត្រូវបានធ្វើកំណាយនៅទីតាំងនានាពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន *"បញ្ជីសារពើភ័ណ្ឌនៃជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក"* ត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៣-២០១៥[23]។

៩. ពាក់ព័ន្ធនឹងការជំទាស់របស់មេធាវីការពារក្តី នួន ជា ដែលអះអាងថា 2-TCE-1062 (វឿន វុទ្ធី) ពុំមែនជាអ្នកជំនាញខាងផ្នែកកោសល្យវិច័យ[24] អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការសិក្សាអំពីជើងឯកត្រូវបានបែងចែកដាច់ពី "របាយការណ៍កោសល្យវិច័យ" និង ត្រូវបានកំណត់ថាជា "ការ

---

[21] ប្រវត្តិរូបសង្ខេបរបស់ វឿន វុទ្ធី, ឯកសារ E3/10678, *សូមមើលឧទាហរណ៍* កំណាយក្នុងខែ កក្កដា ឆ្នាំ ២00៩ នៅទីតាំងល្អាង ស្ពាន "បុរេប្រវត្តិចំណាស់បំផុតនៅកម្ពុជា", កំណាយនៅខែ មករា-កុម្ភៈ ឆ្នាំ ២00៧ នៅទីតាំងភូមិស្នាយ "ឈាបនដ្ឋានបុរេប្រវត្តិនៅកម្ពុជាភាគពាយ័ព្យ" , កំណាយនៅខែកុម្ភៈ ឆ្នាំ ១៩៩៨ នៃការលើកដីជារង្វង់នៅក្រែក ៦២/៥២, ខេត្តកំពង់ចាម។

[22] ប្រវត្តិរូបសង្ខេបរបស់ វឿន វុទ្ធី, ឯកសារ E3/10678, *សូមមើលឧទាហរណ៍* វឿន វុទ្ធី, ២00២, *ឆ្អឹងត្រីពីអង្គរបុរី, ការស្រាវជ្រាវថ្មីៗស្តីពីបុរេប្រវត្តិនៃកម្ពុជា,* ក្នុង *Southeast Asian Archaeology,* ទំព័រ ២៨៩-២៩៤។ វឿន វុទ្ធី និង ស្វ, ពាង, ១៩៩៩៖ *សម្ភារកម្មប្រៀបធៀបនៃឆ្អឹងត្រីសម្រាប់បុរាណវិទ្យា និងសារៈសំខាន់នៃចម្លាក់ត្រីសម័យអង្គរ*។ វឿន វុទ្ធី និង DRIESCH, Angela von den, 2003, *របាយការណ៍បឋមស្តីពីឆ្អឹងត្រីពីអង្គរបុរីនៅដីសណ្តរមេគង្គ, ភ្នំពេញ កម្ពុជា*។ វឿន វុទ្ធី, 2005។ *ឆ្អឹងត្រីពីទីតាំងព្រៃក្មេង ស្រុកពួក សៀមរាប កម្ពុជា*។ វឿន វុទ្ធី, 2005, *ការវិភាគឆ្អឹងត្រីពីទីតាំងឡុងកាង វៀតណាម*។ វឿន វុទ្ធី, 2004, *ការពិពណ៌នាអំពីចម្លាក់លៀនរូបត្រីនៅអង្គរវត្ត និងប្រាសាទបាយ័ន្ត*។ ព្រឹត្តិប័ត្រនិស្សិត, សកលវិទ្យាល័យបុរាណវិទ្យា, លេខ ៣, ទំព័រ ៣៩-៥៦។ វឿន វុទ្ធី, 2006, *ត្រីទឹកសាបនៅកម្ពុជា, សម្ភារកម្មឆ្អឹងត្រីប្រៀបធៀបនៅមហាវិទ្យាល័យបុរាណវិទ្យា, RUFA*។ វឿន វុទ្ធី, 2006, *ត្រីទឹកសាបនៅកម្ពុជា, សម្ភារកម្មឆ្អឹងត្រីប្រៀបធៀបនៅមហាវិទ្យាល័យបុរាណវិទ្យា, RUFA*។ O'Reilly, D., Driesch, A., និង វឿន វុទ្ធី, 2006, ការសិក្សាអំពីវត្ថុបុរាណ និងការសិក្សាអំពីឆ្អឹងសត្វនៅភូមិស្នាយ៖ ឈាបនដ្ឋានបុរេប្រវត្តិចុងក្រោយនៅកម្ពុជាប៉ែកពាយ័ព្យ", *Asian Perspectives,* vol. 45។

[23] ប្រវត្តិរូបសង្ខេបរបស់ វឿន វុទ្ធី, ឯកសារ E3/10678, *សូមមើលផងដែរ* វឿន វុទ្ធី, ២០១៦, *បញ្ជីសារពើភ័ណ្ឌនៃជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ក្រាំងតាចាន់ក្នុងខេត្តតាកែវ*។ វឿន វុទ្ធី ២០១៥, *បញ្ជីសារពើភ័ណ្ឌនៃជនរងគ្រោះក្នុងអំឡុងរបប ប៉ុល ពត នៅវត្តព្រះធាតុស្នួស្តី ក្នុងខេត្តតាកែវ*។ វឿន វុទ្ធី, ២០១៤, *បញ្ជីសារពើភ័ណ្ឌនៃជនរងគ្រោះក្នុងអំឡុងរបប ប៉ុល ពត នៅវត្តប្រាសាទវត្តីក្នុងខេត្តកំពង់ចាម*។

[24] សារណារបស់ នួន ជា, កថាខណ្ឌ ១៩។

សិក្សាអំពីអដ្ឋិធាតុ (ឆ្អឹង) ដោយផ្តោតលើការប៉ះទង្គិចទៅលើឆ្អឹងលលាដ៏ក្បាល”[25]។ លើសពីនេះទៀត ដូចដែលអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីរួចមកហើយថា 2-TCE-1062 (វឿន វុទ្ធី) មានជំនាញអដ្ឋិវិទ្យា[26] ហើយមេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា គាត់មាន “ជំនាញដែលមិនអាចបដិសេធបាន” នៅក្នុងជំនាញផ្នែកនេះ[27]។ ដូចដែលមេធាវីការពារក្តី នួន ជា បានស្នើសុំ 2-TCE-1062 (វឿន វុទ្ធី) ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មស្តីពីវិធីសាស្ត្រ និង ដំណើរការដែលបានប្រើប្រាស់ក្នុងការរៀបចំការសិក្សាអំពីជើងឯក[28]។ អង្គជំនុំជម្រះយល់ឃើញថា ការសិក្សានេះតម្រូវឲ្យមានការពិនិត្យជាលក្ខណៈបច្ចេកទេសលើឆ្អឹងមនុស្សដែលបានរកឃើញក្នុងតំបន់នេះ និង បង្កើតជាទិន្នន័យលម្អិត និងពេញលេញ រួមមានសញ្ញានៃការប៉ះទង្គិចនានាដែលអាចមានជាក់ស្តែងនៅលើឆ្អឹង ហើយនេះជាជំនាញរបស់អ្នកនិពន្ធនៃការសិក្សានេះ។ ហេតុនេះ អង្គជំនុំ-ជម្រះយល់ឃើញថា ការលើកឡើងរបស់មេធាវីការពារក្តីអំពីភាពខ្វះបទពិសោធន៍ផ្នែកកោស-ល្យវិច័យរបស់ 2-TCE-1062 (វឿន វុទ្ធី) ពុំមានទាក់ទិននឹងសមត្ថភាពរបស់គាត់ក្នុងការផ្តល់ ភ័ស្តុតាងពាក់ព័ន្ធនឹងការសិក្សាអំពីជើងឯកនោះឡើយ។

១០. ស្រដៀងគ្នានេះផងដែរ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ដែលថានៅកម្ពុជា “មិនមាន” អ្នកជំនាញលើកំណាយរណ្តៅ មិនប៉ះពាល់ដល់ការវាយតម្លៃអំពីជំនាញរបស់ 2-TCE-1062 (វឿន វុទ្ធី) ទាក់ទិននឹងការសិក្សាអំពីជើងឯកឡើយ[29]។ ជាក់ស្តែង ក្នុងសេចក្តីសង្កេតខាងដើមរបស់ខ្លួនស្តីពីការសិក្សាអំពីជើងឯក មេធាវីការពារក្តី នួន ជា បានលើកឡើងថា យថាភាព *ការបញ្ជាក់បឋម* នៃការសិក្សានេះ មិនអាចត្រូវបានជំទាស់ឡើយ “ដោយសារវាត្រូវបានរៀបចំឡើងនៅក្រោមការត្រួតពិនិត្យរបស់លោក វឿន វុទ្ធី ដែលបច្ចុប្បន្ននេះជាប្រធាននាយកដ្ឋានបុរាណវិទ្យា និង បុរេ

---

[25]ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និង ការក្រើនរម្លឹកទាក់ទងនឹងសំណើសុំនានា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត, ឯកសារ E404, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦, កថាខណ្ឌ ២។

[26] សារអេឡិចត្រូនិកពីអង្គជំនុំជម្រះសាលាដំបូងទៅភាគីចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦, ឯកសារ E404/7.1.2។

[27] សារណារបស់ នួន ជា, កថាខណ្ឌ ១៨។

[28] ឯកសារ E404/4, កថាខណ្ឌ ៧។ *សូមមើលផងដែរ* សេចក្តីសង្កេតរបស់ នួន ជា អំពីការទទួលយកការសិក្សាស្តីពីអដ្ឋិធាតុនៅជើងឯក និងការវាយតម្លៃខាងក្រៅ, ឯកសារ E404/2 ជាមួយឧបសម្ព័ន្ធ, ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦, (“សេចក្តីសង្កេតរបស់ នួន ជា”), កថាខណ្ឌ ២៤។

[29] *ផ្ទុយ* ដីកាជំទាស់សំណើសុំយោបល់អ្នកជំនាញទីពីរ (សំណើលើកទី២៦របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ), ឯកសារ D356/1, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០, កថាខណ្ឌ ៨ *ជាមួយ* សារណារបស់ នួន ជា, កថាខណ្ឌ ១៩។

ប្រវត្តិសាស្ត្រនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ជាប្រធានមន្ទីរពិសោធន៍អដ្ឋិធាតុ និង អភិរក្សនៃមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក នៅភ្នំពេញ"[30]។

១១. បន្ទាប់ពីបានយល់ឃើញថា 2-TCE-1062 (វឿន វុទ្ធី) ពុំមែនជាអ្នកជំនាញផ្នែកកោសល្យវិច័យ ហើយការសិក្សាអំពីជើងឯក ពុំមែនជារបាយការណ៍កោសល្យវិច័យនោះ អង្គជំនុំជម្រះពុំចាំបាច់ពិចារណាទៅលើសារណារបស់មេធាវីការពារក្តី នួន ជា ទាក់ទិននឹង "ដំណើរការកោសល្យវិច័យ" និង "ទិសដៅនៃការងារកោសល្យវិច័យ" ឡើយ[31]។

១២. ផ្អែកលើបទពិសោធន៍ការងារ ការបណ្តុះបណ្តាល និង ការស្រាវជ្រាវដ៏ទូលំទូលាយ ដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា 2-TCE-1062 (វឿន វុទ្ធី) ពិតជាមានគុណវុឌ្ឍិជាអ្នកជំនាញផ្នែកអដ្ឋិធាតុ ហើយថាគាត់មានចំណេះដឹង ជំនាញ និងបទពិសោធន៍ ដែលអាចជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃទៅលើភ័ស្តុតាង ជាពិសេសទាក់ទងនឹងការសិក្សាអំពីជើងឯក និង សម្ភារៈពាក់ព័ន្ធនានា។ អង្គជំនុំជម្រះកត់សម្គាល់ថា សម្ភារៈពាក់ព័ន្ធនានាដែលរួមមានឯកសារដែលត្រូវបានទទួលយកជាឯកសារភ័ស្តុតាង នៅក្នុងឯកសារ E404/4 និង ឯកសារនានាដែលភាគីអាចរកបាននៅក្នុងឯកសារ E404/4/3[32]។ ជាចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា ប្រសិនបើការសិក្សាអំពីក្រាំងតាចាន់ ដែលមាននៅក្នុងឯកសារ E404/4/3 ត្រូវបានទទួលយកជាឯកសារភ័ស្តុតាង និង អនុញ្ញាតឱ្យភាគីប្រើប្រាស់បានមុនពេល 2-TCE-1062 (វឿន វុទ្ធី) មកផ្តល់សក្ខីកម្ម គាត់ក៏អាចផ្តល់ចម្លើយនានា ពាក់ព័ន្ធនឹងឯកសារនេះផងដែរ។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**តែងតាំង** 2-TCE-1062 (វឿន វុទ្ធី) ជាអ្នកជំនាញលើផ្នែកអដ្ឋិធាតុ និង សម្រេចកោះហៅគាត់ឱ្យមកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះ ស្តីពីបញ្ហាទាំងឡាយដែលស្ថិតក្នុងចំណេះដឹង ឬ ជំនាញរបស់គាត់ ពាក់ព័ន្ធការសិក្សាស្តីពីជើងឯក និង សម្ភារៈពាក់ព័ន្ធ ព្រមទាំងបញ្ហានានាដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០២។

---

[30] សេចក្តីសង្កេតរបស់ នួន ជា, កថាខណ្ឌ ១៨។

[31] សារណារបស់ នួន ជា, កថាខណ្ឌ ២០។

[32] ឯកសារ វឿន វុទ្ធី, E404/4/3 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

E404/8

០០២/១៩-០៩-២០០៧-អវតក/អជសង

**ទទួលយក** ប្រវត្តិរូបការងាររបស់ 2-TCE-1062 (រឿន វុទ្ធី) ធ្វើជាឯកសារភ័ស្តុតាង និង **ដាក់លេខ** E3/10678 សម្រាប់ឯកសារនេះ និង

**ណែនាំ** ឱ្យមេធាវីការពារក្តី នួន ជា ជាអ្នកចាប់ផ្តើមតាំងសំណួរចំពោះ 2-TCE-1062 (រឿន វុទ្ធី) មុនភាគីដទៃទៀតក្នុងពេលសវនាការ អនុលោមតាមវិធាន ៩១ និង ៩១ *ស្ទួន* នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C

**និល ណុន**